Australian Government
Department of Social Services

# ការរំលោភបំពានបណ្ណាការ

## អំពើហិង្សា ឬការបៀតបៀនយាយីទាក់ទិននឹងបណ្ណាការ គឺជាទម្រង់នៃអំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ។

ប្រពៃណីបណ្ណាការ អាចខុសគ្នាទៅតាមប្រទេស និងវប្បធម៌នីមួយៗ។

'បណ្ណាការ' គឺជាទំនៀមទម្លាប់មួយដែលសំដៅទៅលើប្រាក់ ទ្រព្យសម្បត្តិ ឬអំណោយ ដែលត្រូវបានផ្ទេរជាទូទៅដោយគ្រួសាររបស់ស្ត្រី ទៅស្វាមីរបស់ខ្លួននៅពេលរៀបការ។ ការប្រើប្រាស់បណ្ណាការជាបណ្ណាការ មិនមែនជាទម្រង់នៃការរំលោភបំពានទេ។

រាល់សកម្មភាពនៃការបង្ខិតបង្ខំ អំពើហិង្សា ឬការបៀតបៀនយាយីដែលទាក់ទងនឹងការផ្តល់ ឬការទទួលបានបណ្ណាការនៅពេលណាមួយ មុន ក្នុងអំឡុងពេល ឬក្រោយអាពាហ៍ពិពាហ៍ គឺជាទម្រង់នៃការរំលោភបំពាន។ ការរំលោភបំពានដែលទាក់ទងនឹងបណ្ណាការ ជាទូទៅជាប់ពាក់ព័ន្ធនឹងការអះអាងថាបណ្ណាការមិនបានបង់ឱ្យ ហើយមានការទាមទារដោយបង្ខិតបង្ខំដើម្បីចង់បានលុយ ឬអំណោយបន្ថែមពីស្ត្រី និងក្រុមគ្រួសារធំរបស់ខ្លួន។

អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ គឺជាបទឧក្រិដ្ឋ នៅក្នុងប្រទេសអូស្ត្រាលី។ ជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ អាចជាប់ពន្ធនាគារ ទោះបីអ្នកនោះជាបុរស ឬស្ត្រីក៏ដោយ។

| |
|---|
| ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។ |
| ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។ |
| សម្រាប់ការប្រឹក្សាយោបល់ និងការផ្តល់ព័ត៌មានជាសម្ងាត់ ហើយឥតគិតថ្លៃ សូមទូរស័ព្ទទៅ 1800RESPECT លេខ **1800 737 732**។ |
| ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទទៅលេខ **131 450**។ |

## នៅក្នុងស្ថានភាពបែបណាក៏ដោយ រដ្ឋាភិបាលអូស្ត្រាលីមិនអត់ឱនចំពោះអំពើហិង្សា ឬការបៀតបៀនយាយីទាក់ទិននឹងបណ្ណាការឡើយ។

Australian Government ចាត់ទុកអំពើហិង្សាក្នុងគ្រួសារដូចជា អំពើហិង្សា ឬការបៀតបៀនយាយីទាក់ទិននឹងបណ្ណាការយ៉ាងធ្ងន់ធ្ងរជាទីបំផុត។ ប្រជាជនអូស្ត្រាលីទាំងអស់មានសិទ្ធិរស់នៅដោយគ្មានអំពើហិង្សា ការភ័យខ្លាច ឬការបង្ខិតបង្ខំ ដោយមិនគិតពីការអនុវត្តជំនឿ សាសនា និងវប្បធម៌របស់ពួកគេឡើយ។

អំពើហិង្សា ឬការបៀតបៀនយាយីទាក់ទិននឹងបណ្ណាការ រួមមានឥរិយាបថ ឬការគំរាមកំហែងដែលមានបំណងគ្រប់គ្រងដៃគូ ឬក្រុមគ្រួសាររបស់ពួកគេ ដោយបង្កឱ្យមានការភ័យខ្លាច ឬការគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ។

## ប្រសិនបើអ្នករស់នៅក្រោមទិដ្ឋាការ អ្នកនៅតែអាចទទួលបានជំនួយ។

ដៃគូ សមាជិកគ្រួសារ ឬជនផ្សេងទៀតក្នុងសហគមន៍ មិនអាចគំរាមកំហែងដល់ស្ថានភាពនៃទិដ្ឋាការរបស់អ្នកបានឡើយ។

ប្រសិនបើអ្នកកាន់ទិដ្ឋាការដៃគូបណ្តោះអាសន្ន (ថ្នាក់រង 309 ឬ 820) ឬទិដ្ឋាការអាពាហ៍ពិពាហ៍អនាគត (ថ្នាក់រង 300) ហើយទទួលរងនូវអំពើហិង្សាក្នុងគ្រួសារទាក់ទិននឹងបណ្ណាការ គឺមានមាត្រាច្បាប់អំពើហិង្សាក្នុងគ្រួសារ នៅក្នុងច្បាប់អន្តោប្រវេសន៍របស់ប្រទេសអូស្ត្រាលី ដែលអនុញ្ញាតឱ្យអ្នកបន្តដាក់ពាក្យសុំយកទិដ្ឋាការដៃគូអចិន្ត្រៃយ៍ (ថ្នាក់រង 100 ឬ 801) បាន។

## បណ្ណាការមិនអាចយកប្រើ ដើម្បីបង្ខំជនណាម្នាក់ឱ្យរៀបការបានឡើយ។

ប្រសិនបើបណ្ណាការត្រូវបានគេយកប្រើជាមធ្យោបាយដើម្បីបង្ខំឱ្យមនុស្សម្នាក់ឲ្យរៀបការ ដោយគ្មានការយល់ព្រមទាំងស្រុង និងតាមសេរីភាពរបស់ខ្លួន ការនេះអាចចាត់ទុកជាអាពាហ៍ពិពាហ៍ដោយបង្ខំ។

នៅក្នុងប្រទេសអូស្ត្រាលី មនុស្សគ្រប់រូបមានសេរីភាពក្នុងការជ្រើសរើសថាតើនរណា និងពេលណាដែលពួកគេរៀបការ។ វាជាការប្រឆាំងនឹងច្បាប់ប្រទេសអូស្ត្រាលីដែលបង្ខំ គំរាមកំហែង ឬបញ្ឆោតនរណាម្នាក់ឱ្យរៀបការ។ វាក៏ប្រឆាំងនឹងច្បាប់ដែរដែលលើកទឹកចិត្ត ឬជួយរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ និងចូលរួមជាភាគីដោយបង្ខំឱ្យរៀបការ ប្រសិនបើអ្នកមិនមែនជាជនរងគ្រោះ។ ការនេះអនុវត្តចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ តាមវប្បធម៌ និងសាសនា។

## មានសេវាយល់ដឹងពីវប្បធម៌នៅក្នុងប្រទេសអូស្ត្រាលីដែលអាចជួយបាន។

**1800RESPECT** គឺជាសេវាផ្តល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី។ សេវានេះផ្តល់ព័ត៌មាន និងការប្រឹក្សាតាមទូរស័ព្ទ និងអ៊ីនធើណិតដោយឥតគិតថ្លៃ និងដោយសម្ងាត់។ អ្នកផ្តល់ការប្រឹក្សានឹងស្តាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅកាន់សេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

ចូរទូរស័ព្ទទៅលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ **1800RESPECT** នៅត្រង់ **www.1800RESPECT.org.au**។

**មេឃខៀវខ្ចីរបស់ខ្ញុំ** (**My Blue Sky**) គឺជាវិបសាយជាតិរបស់ប្រទេសអូស្ត្រាលី និងជាបណ្តាញជំនួយដែលបានរៀបចំពិសេសដើម្បីទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព័ត៌មាន ការបញ្ជូន និងការផ្តល់ដំបូន្មានផ្នែកច្បាប់ដោយឥតគិតថ្លៃ។

ចូរទូរស័ព្ទទៅលេខ **(02) 9514 8115** ផ្ញើសារទៅលេខ **0481 070 844** អ៊ីម៉ែលទៅ **help@mybluesky.org.au** ឬចូលទៅកាន់វិបសាយរបស់ **My Blue Sky** នៅត្រង់ **www.mybluesky.org.au**

ព័ត៌មានបន្ថែមស្តីពីអំពើហិង្សាក្នុងគ្រួសារ និងទិដ្ឋាការ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការជួញដូរមនុស្ស មាននៅតាមវិបសាយរបស់ **ក្រសួងកិច្ចការក្នុងប្រទេស** (**Department of Home Affairs**) នៅត្រង់ **www.homeaffairs.gov.au** ហើយស្វែងរកពាក្យ "អាពាហ៍ពិពាហ៍ដោយបង្ខំ"។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅ **សេវាបកប្រែភាសាសរសេរ និងនិយាយ** (**Translating and Interpreting Service**) (TIS) ដោយឥតគិតថ្លៃលេខ **131 450**។ TIS អាចជួយអ្នកស្វែងរកសេវាផ្សេងៗទៀតបាន ក៏ប៉ុន្តែ TIS មិនផ្តល់ការប្រឹក្សាទេ។ គ្រប់ការហៅទូរស័ព្ទទាំងអស់គឺឥតគិតថ្លៃ និងសម្ងាត់។